សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
ASIA EURO UNIVERSITY

លេខៈ ០៤៨/១៥ សអអ/បផក

# បទបញ្ជាផ្ទៃក្នុង
# សម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ
# នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

## សាកលវិទ្យាធិការ

- បានឃើញអនុក្រឹត្យលេខ០៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ ស្តីពីការទទួលស្គាល់ការប្រែក្លាយពីវិទ្យាស្ថាន អាស៊ី អឺរ៉ុប ទៅជាសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- បានឃើញប្រកាសលេខ១៤៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យលម្អិតសម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
- បានឃើញសេចក្តីសម្រេចលេខ២៨៥/១៥ សអអ/សសរ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- បានឃើញសេចក្តីសម្រេចលេខ៣០៨/១៥ សអអ/សសរ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ
- បានឃើញសេចក្តីសម្រេចលេខ៤៣/១៥ សអអ/សសរ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីគោលការណ៍ណែនាំលម្អិតសម្រាប់ការបណ្តុះបណ្តាលថ្នាក់បណ្ឌិត
- បានឃើញសេចក្តីសម្រេចលេខ៤២៦/១៥ សអអ/សសរ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីគោលការណ៍ណែនាំលម្អិតសម្រាប់ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
- យោងស្មារតីអង្គប្រជុំថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការពិភាក្សានិងអនុម័តលើបទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប
- តាមសំណើរបស់លោកបណ្ឌិត **ទ្រី ចាន់ធុច** ប្រធានអង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥
- យោងតាមការចាំបាច់សម្រាប់ការបណ្តុះបណ្តាលសម្រាប់ថ្នាក់ក្រោយបរិញ្ញាបត្រ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-គោលបំណង**

បទបញ្ជាផ្ទៃក្នុងនេះ មានគោលបំណងធានាឱ្យមានការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រ នៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ប្រកបដោយគុណភាព និងប្រសិទ្ធភាព ព្រមទាំងអ្នកសិក្សាស្រាវជ្រាវទទួលបាន



អគ្គការ អាស៊ី អឺរ៉ុប
#832,Kampuchea Krom Blvd, Toek Laak I,Tuol Kork, Phnom Penh, Cambodia.
HP: 017 27 06 86 / 077 72 56 68

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប (ទីស្នាក់ការកណ្តាល)
#826, Kampuchea Krom Blvd,Toek Laak I
Tuol Kok, Phnom Penh, Cambodia. Postal Code:12156
HP: 015 72 00 72 / 012 48 17 38
Phone/Fax: 023 998 124 / E-mail: info@aeu.edu.kh/ website: www.AEU.edu.kh

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប (អគារមាស)
Hotel - Restaurant - Cisco Tangberg
Court Room - Conference Hall - Lab - Gym...
#60, St. 146⊥257, Toek Laak II, Tuol Kork
Phnom Penh Cambodia.

ចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ ចេះស្រឡាញ់និងការពារសម្បត្តិវប្បធម៌ជាតិ អត្តសញ្ញាណជាតិ និងភាសាជាតិ ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការកសាងជាតិនិងសង្គម។

**ប្រការ២.-គោលដៅ**

បទបញ្ជាផ្ទៃក្នុងនេះមានគោលដៅ ៖

- កំណត់អំពីវិធាន លក្ខខណ្ឌ និងរបៀបរបបសិក្សាស្រាវជ្រាវសម្រាប់ថ្នាក់ក្រោយបរិញ្ញាបត្រ
- ជួយឱ្យនិស្សិតបានរៀបចំលក្ខណសម្បត្តិរបស់ខ្លួនបានត្រឹមត្រូវ ដើម្បីទទួលបានជោគជ័យក្នុងការសិក្សារហូតដល់ទីបញ្ចប់។

**ប្រការ៣.-បញ្ញត្តិ**

គ្មានឃ្លាឬប្រយោគណានៅក្នុងបទបញ្ជាផ្ទៃក្នុងនេះ ទៅបកស្រាយខុសពីការពិតឡើយ។ ចំពោះចំណុចណាមួយដែលមានការយល់មិនច្បាស់លាស់ ត្រូវសួរបញ្ជាក់ដោយផ្ទាល់ជាមួយគណៈគ្រប់គ្រង ឬបុគ្គលិកជាន់ខ្ពស់ នៃអង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ (អគប)។

ការប្រព្រឹត្តខុសពីបទបញ្ជាផ្ទៃក្នុងនេះ នឹងត្រូវទទួលពិន័យ។

## ជំពូកទី២

## លក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសនិស្សិតឱ្យចូលរៀន

### ផ្នែកទី១ ៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

**ប្រការ៤.-នីតិវិធីនៃការជ្រើសរើសនិស្សិត**

អគប ត្រូវបានកំណត់ការជ្រើសរើសនិស្សិតឱ្យចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ទៅតាមការកំណត់របស់សាកលវិទ្យាល័យ។

និស្សិតដែលត្រូវជ្រើសរើសទាំងអស់ ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលរៀបចំដោយសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប និងមានការចូលរួមពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៥.-លក្ខខណ្ឌសម្រាប់ការជ្រើសរើស**

ការចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- បានឆ្លងកាត់ការសិក្សាគ្រប់កម្រិតបណ្តុះបណ្តាលក្នុងគ្រឹះស្ថានឧត្តមសិក្សា ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- ទទួលបានពិន្ទុមធ្យមភាគសរុប (GPA) ចាប់ពី ២,៥ឡើងទៅ ឬនិស្សិតសរសេរសារណាក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រ។ ករណីទទួលបានពិន្ទុមធ្យមភាគសរុប (GPA) ទាបជាង ២,៥ និស្សិតត្រូវសិក្សាបំពេញបន្ថែមទៅលើមុខវិជ្ជាឯកទេសរបស់ខ្លួនទៅតាមស្ថានភាពជាក់ស្តែង
- ត្រូវឆ្លងកាត់ការប្រឡងជ្រើសរើសចូលរៀន ដែលរៀបចំដោយសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប និងមានការចូលរួមពីក្រសួងអប់រំ យុវជន និងកីឡា ហើយវិញ្ញាសាប្រឡងមាន (១)វិញ្ញាសាមុខវិជ្ជាជំនាញ និង (២)វិញ្ញាសាភាសាអង់គ្លេស
- មានមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ។

**ប្រការ៦.-សំណុំលិខិតនិស្សិត**

និស្សិតត្រូវមានសំណុំលិខិតដូចខាងក្រោម ៖

- ប្រវត្តិរូបសង្ខេបរបស់និស្សិត មួយ (១)ច្បាប់

- ពាក្យចុះឈ្មោះចូលរៀនរបស់និស្សិត មួយ (១)ច្បាប់
- ច្បាប់ថតចម្លងសញ្ញាបត្របរិញ្ញាបត្រ (ដោយមានការបញ្ជាក់ពីសាលារាជធានី ឬសាលាខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌមានសមត្ថកិច្ច និងគ្រឹះស្ថានបណ្តុះបណ្តាល)
- ព្រឹត្តិបត្រពិន្ទុដែលបានសិក្សានៅថ្នាក់បរិញ្ញាបត្រ មួយ (១)ច្បាប់
- រូបថតបច្ចុប្បន្ន ៤គុណ៦ ចំនួន ៦សន្លឹក (ពាក់អាវធំនិងក្រវ៉ាត់ក សម្រាប់និស្សិតប្រុស និង ពាក់អាវប៉ាក់ពណ៌ស សម្រាប់និស្សិតស្រី)
- វិញ្ញាបនបត្របញ្ជាក់កម្រិតមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវ ដែលទទួលស្គាល់ដោយមជ្ឈមណ្ឌលព័ត៌មានវិទ្យា នៃសអអ។

**ប្រការ៧.-ការរៀបចំយន្តការប្រឡងជ្រើសរើស**

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគណៈកម្មការប្រឡងជ្រើសរើស ដែលមានសមាសភាពដូចខាងក្រោម៖

- គណៈកម្មការសម្រេចនិងប្រកាសលទ្ធផលចុងក្រោយ
- គណៈមេប្រយោគ។

គណៈកម្មការប្រឡងជ្រើសរើសនេះ មានសិទ្ធិបង្កើតគណៈកម្មការកណ្តាល និងគណៈកម្មការផ្សេងៗទៀតតាមតម្រូវការចាំបាច់ ដើម្បីឱ្យដំណើរការប្រឡងជ្រើសរើសប្រព្រឹត្តទៅដោយប្រសិទ្ធភាពនិងមានតម្លាភាព។

តួនាទីនិងភារកិច្ចគណៈកម្មការកណ្តាល និងគណៈកម្មការផ្សេងៗទៀត ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៨.-ការប្រកាសលទ្ធផលជ្រើសរើស**

គណៈកម្មការប្រឡងជ្រើសរើសត្រូវរៀបចំរបាយការណ៍ និងលទ្ធផលនៃការប្រឡងជ្រើសរើសដើម្បីជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេច។

## ផ្នែកទី២ ៖ ថ្នាក់បណ្ឌិត

**ប្រការ៩.-នីតិវិធីនៃការជ្រើសរើសនិស្សិត**

អគប ត្រូវបានកំណត់ការជ្រើសរើសនិស្សិតឱ្យចូលសិក្សាថ្នាក់បណ្ឌិតតែមួយលើកគត់ក្នុងមួយឆ្នាំសិក្សា។

ការប្រឡងជ្រើសរើសនេះ ត្រូវធ្វើឡើងតាមរូបភាពពីរ៖ ទី១-ការពិនិត្យសំណុំឯកសារ និងទី២-ការសម្ភាសន៍និងវាយតម្លៃលើសំណើគម្រោងស្រាវជ្រាវបឋមដោយផ្ទាល់។

**ប្រការ១០.-លក្ខខណ្ឌសម្រាប់ការជ្រើសរើស**

ការចូលសិក្សាថ្នាក់បណ្ឌិត និស្សិតត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- បានឆ្លងកាត់ការសិក្សាគ្រប់កម្រិតបណ្តុះបណ្តាលក្នុងគ្រឹះស្ថានឧត្តមសិក្សា ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា
- ទទួលបានពិន្ទុមធ្យមភាគសរុប (GPA) ចាប់ពី ៣,០០ឡើងទៅ ឬនិស្សិតសរសេរ និក្ខេបបទក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។ ករណីទទួលបានពិន្ទុមធ្យមភាគសរុប (GPA) ទាបជាង ៣,០០ បេក្ខជនត្រូវសិក្សាបំពេញបន្ថែមទៅលើមុខវិជ្ជាឯកទេសរបស់ខ្លួនទៅតាមស្ថានភាពជាក់ស្តែង។
- មានសំណើគម្រោងស្រាវជ្រាវបឋមច្បាស់លាស់

- មានសមត្ថភាពខាងភាសាអន្តរជាតិមួយ
- មានមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ។

**ប្រការ១១.-សំណុំលិខិតបេក្ខជន**

បេក្ខជនត្រូវមានសំណុំលិខិតដូចខាងក្រោម ៖

- ពាក្យចុះឈ្មោះចូលរៀនរបស់បេក្ខជនមួយ (១)ច្បាប់
- ប្រវត្តិរូបសង្ខេបរបស់បេក្ខជនមួយ (១)ច្បាប់
- លិខិតបិទជិតរបស់អ្នកផ្តល់យោបល់បី (៣)រូប (អ្នកគ្រប់គ្រង១រូប និងសាស្ត្រាចារ្យធ្លាប់ណែនាំ២រូប)
- ច្បាប់ថតចម្លងសញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ (ដោយមានការបញ្ជាក់ពីសាលារាជធានី ឬសាលាខេត្ត ឬសាលាក្រុង ស្រុក ខណ្ឌមានសមត្ថកិច្ច និងគ្រឹះស្ថានបណ្តុះបណ្តាល)
- ព្រឹត្តិបត្រពិន្ទុដែលបានសិក្សានៅថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មួយ (១)ច្បាប់
- វិញ្ញាបនបត្របញ្ជាក់កម្រិតភាសាអង់គ្លេស ដែលទទួលស្គាល់ដោយមជ្ឈមណ្ឌល បណ្តុះបណ្តាល និងប្រឡង TOEFL ឬ IELTS នៃសអអ
- វិញ្ញាបនបត្របញ្ជាក់កម្រិតមូលដ្ឋានគ្រឹះព័ត៌មានវិទ្យាសម្រាប់ការស្រាវជ្រាវ ដែលទទួលស្គាល់ដោយមជ្ឈមណ្ឌលព័ត៌មានវិទ្យា នៃសអអ
- សំណើគម្រោងស្រាវជ្រាវបឋម។

**ប្រការ១២.-ការរៀបចំយន្តការប្រឡងជ្រើសរើស**

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគណៈកម្មការប្រឡងជ្រើសរើស ដែលមានសមាសភាពដូចខាងក្រោម៖

- គណៈកម្មការពិនិត្យនិងសម្រេចលទ្ធផលចុងក្រោយ
- គណៈមេប្រយោគ។

គណៈកម្មការប្រឡងជ្រើសរើសនេះ មានសិទ្ធិបង្កើតគណៈកម្មការកណ្តាល អនុគណៈកម្មការមុខជំនាញ និងអនុគណៈកម្មការផ្សេងៗទៀតតាមតម្រូវការចាំបាច់ ដើម្បីឱ្យដំណើរការប្រឡងជ្រើសរើសប្រព្រឹត្តទៅដោយប្រសិទ្ធភាពនិងមានតម្លាភាព។

តួនាទីនិងភារកិច្ចគណៈកម្មការកណ្តាល អនុគណៈកម្មការមុខជំនាញ និងអនុគណៈកម្មការផ្សេងៗទៀត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ១៣.-យន្តការជ្រើសរើស**

ការប្រឡងជ្រើសរើសនិស្សិតថ្នាក់បណ្ឌិតត្រូវធ្វើឡើងជាពីរជំហាន។ **ជំហានទីមួយ ត្រូវធ្វើឡើងដោយ**ការពិនិត្យសំណុំលិខិតបេក្ខជន និងជំហានទីពីរ គឺការវាយតម្លៃលើការឡើងបង្ហាញសំណើស្រាវជ្រាវបឋមរបស់បេក្ខជន។

ដោយឡែកសម្រាប់បេក្ខជនបណ្ឌិតវិជ្ជាជីវៈ ជំហានទីមួយ ត្រូវពិនិត្យនិងវាយតម្លៃទៅលើសំណុំឯកសារបេក្ខជន ស្រង់ស្ថិតិបទពិសោធវិជ្ជាជីវៈ និងការធ្លាប់បោះពុម្ពផ្សាយ និងពិនិត្យគម្រោងស្រាវជ្រាវបឋមរបស់បេក្ខជន និងជំហានទីពីរ ត្រូវឡើងបង្ហាញសំណើគម្រោងស្រាវជ្រាវបែបសកម្មភាពរបស់បេក្ខជន។

**ប្រការ១៤.-ការប្រកាសលទ្ធផលជ្រើសរើស**

គណៈកម្មការប្រឡងជ្រើសរើសត្រូវរៀបចំរបាយការណ៍ និងលទ្ធផលនៃការប្រឡងជ្រើសរើសដើម្បីជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេច។

## ជំពូកទី៣
## កម្មវិធីសិក្សានិងការបង្រៀន
## ផ្នែកទី១ ៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

**ប្រការ១៥.-រយៈពេលសិក្សា**

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ តម្រូវឱ្យសិក្សារយៈពេល ២ឆ្នាំ សម្រាប់ការសិក្សាពេញម៉ោង ហើយរហូតដល់ ៦ ឬ ៨ឆ្នាំ សម្រាប់ការសិក្សាមិនពេញម៉ោង បន្ថែមលើការសិក្សាកម្រិតបរិញ្ញាបត្រ និងមានចំនួនក្រេឌីតសរុបយ៉ាងតិច ៤៥ ក្រេឌីត។

ការសិក្សាមុខវិជ្ជានីមួយៗ មានឈ្មោះមុខវិជ្ជា និងគម្រោងខ្លឹមសារដែលកំណត់ដោយក្រុមមុខជំនាញនីមួយ។

**ប្រការ១៦.-តាមរយៈការសិក្សាលើមុខវិជ្ជា**

ក/ ការបណ្តុះបណ្តាលតាមរយៈការសិក្សាលើមុខវិជ្ជាទាំងអស់ ដោយផ្អែកលើការប្រឡងជាសំណេរ តម្រូវឱ្យនិស្សិតសិក្សាដូចខាងក្រោម៖

| | |
|---|---|
| - មុខវិជ្ជារួម | ១២ ក្រេឌីតសិក្សា |
| - មុខវិជ្ជាជំនាញ | ១៥ ក្រេឌីតសិក្សា |
| - មុខវិជ្ជាជ្រើសរើស | ១២ ក្រេឌីតសិក្សា |
| - មុខវិជ្ជាប្រឡង | ៦ ក្រេឌីតសិក្សា |
| សរុប | ៤៥ ក្រេឌីតសិក្សា |

ខ/ ការបណ្តុះបណ្តាលតាមរយៈការសិក្សាលើមុខវិជ្ជា និងមានការធ្វើគម្រោងស្រាវជ្រាវលើមុខវិជ្ជាណាមួយ តម្រូវឱ្យនិស្សិតសិក្សាដូចខាងក្រោម៖

*១. ការសិក្សាមុខវិជ្ជា ចំនួន ៣៩ ក្រេឌីតសិក្សា ៖*

| | |
|---|---|
| - មុខវិជ្ជារួម | ១២ ក្រេឌីតសិក្សា |
| - មុខវិជ្ជាជំនាញ | ១៥ ក្រេឌីតសិក្សា |
| - មុខវិជ្ជាជ្រើសរើស | ១២ ក្រេឌីតសិក្សា |

*២. ការសរសេរនិងការពារគម្រោងស្រាវជ្រាវ ចំនួន ៦ ក្រេឌីតសិក្សា*

| | |
|---|---|
| សរុប | ៤៥ ក្រេឌីតសិក្សា |

**ប្រការ១៧.-តាមរយៈការសិក្សាលើមុខវិជ្ជានិងស្រាវជ្រាវ**

ការបណ្តុះបណ្តាលធ្វើឡើងតាមរយៈការសិក្សាលើមុខវិជ្ជាតម្រូវ និងការធ្វើរបាយការណ៍ស្រាវជ្រាវ ហើយការបញ្ចប់ការសិក្សាត្រូវផ្អែកលើការប្រឡងសំណេរនិងលទ្ធផលនៃរបាយការណ៍។

កម្មវិធីសិក្សានេះ តម្រូវឱ្យនិស្សិតសិក្សាលើមុខវិជ្ជាចំនួន ៣៣ ក្រេឌីតនៃចំនួនក្រេឌីតសរុប និងចំនួន ១២ ក្រេឌីតលើរបាយការណ៍ស្រាវជ្រាវ ដូចខាងក្រោម៖

*១. ការសិក្សាមុខវិជ្ជា ចំនួន ៣៣ ក្រេឌីតសិក្សា ៖*

| | |
|---|---|
| - មុខវិជ្ជារួម | ៩ ក្រេឌីតសិក្សា |
| - មុខវិជ្ជាជំនាញ | ១២ ក្រេឌីតសិក្សា |
| - មុខវិជ្ជាជ្រើសរើស | ៦ ក្រេឌីតសិក្សា |
| - មុខវិជ្ជាប្រឡង | ៦ ក្រេឌីតសិក្សា |

*២. ការសរសេរនិងការពាររបាយការណ៍ស្រាវជ្រាវ ចំនួន ១២ ក្រេឌីតសិក្សា ៖*

| | | |
|---|---|---|
| - ការពាររបាយការណ៍ស្រាវជ្រាវសាកល្បង | | ៣ ក្រេឌីតសិក្សា |
| - ការចុះផ្សាយអត្ថបទស្រាវជ្រាវ | | ៣ ក្រេឌីតសិក្សា |
| - ការពាររបាយការណ៍ស្រាវជ្រាវបញ្ចប់ | | ៦ ក្រេឌីតសិក្សា |
| | សរុប | ៤៥ ក្រេឌីតសិក្សា |

**ប្រការ១៨.-តាមរយៈការស្រាវជ្រាវ**

ការបណ្តុះបណ្តាលធ្វើឡើងដោយផ្អែកលើការសិក្សាស្រាវជ្រាវជាចម្បង ហើយការបញ្ចប់ការសិក្សាត្រូវផ្អែកលើនិក្ខេបបទនៃការស្រាវជ្រាវ។

កម្មវិធីសិក្សានេះ តម្រូវឱ្យនិស្សិតសិក្សាតែលើមុខវិជ្ជាមូលដ្ឋានចាំបាច់ចំនួន ១២ក្រេឌីត និងចំនួន ៣៣ ក្រេឌីតលើនិក្ខេបបទ ដូចខាងក្រោម៖

*១. ការសិក្សាមុខវិជ្ជាមូលដ្ឋានចាំបាច់ ចំនួន ១២ ក្រេឌីតសិក្សា ៖*

| | |
|---|---|
| - មុខវិជ្ជាស្រាវជ្រាវ | ៦ ក្រេឌីតសិក្សា |
| - មុខវិជ្ជាជំនាញ | ៦ ក្រេឌីតសិក្សា |

*២. ការសរសេរនិងការពារនិក្ខេបបទ ចំនួន ៣៣ ក្រេឌីតសិក្សា ៖*

| | | |
|---|---|---|
| - ការពារគម្រោងស្រាវជ្រាវពិស្តារ | | ៣ ក្រេឌីតសិក្សា |
| - ការចុះផ្សាយអត្ថបទស្រាវជ្រាវ | | ៦ ក្រេឌីតសិក្សា |
| - ការចូលរួមវេទិកាវិទ្យាសាស្ត្រពាក់ព័ន្ធដោយ | | |
| - មានធ្វើបទបង្ហាញ | | ៣ ក្រេឌីតសិក្សា |
| - ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | | ៣ ក្រេឌីតសិក្សា |
| - ការពារនិក្ខេបបទសាកល្បង | | ៦ ក្រេឌីតសិក្សា |
| - ការពារនិក្ខេបបទបញ្ចប់ការសិក្សា | | ១២ ក្រេឌីតសិក្សា |
| | សរុប | ៤៥ ក្រេឌីតសិក្សា |

**ប្រការ១៩.-មុខវិជ្ជាបំពេញបន្ថែម**

ចំពោះនិស្សិតដែលមានបរិញ្ញាបត្រខុសឆ្ងាយពីជំនាញដែលខ្លួនបានជ្រើសរើស សម្រាប់បន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ត្រូវសិក្សាបន្ថែមមុខវិជ្ជាមូលដ្ឋានគ្រឹះនៃជំនាញ ចំនួន ៩ក្រេឌីត។

ការសិក្សាមុខវិជ្ជាបំពេញបន្ថែម ត្រូវធ្វើឡើងនៅដើមឆ្នាំសិក្សាដំបូង។ មុខវិជ្ជាបំពេញបន្ថែម ត្រូវសម្រេចដោយអង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ។

ចាត់ទុកថាទទួលបានជោគជ័យលើគ្រប់មុខវិជ្ជាទាំងអស់ លុះត្រាតែមិនមានមុខវិជ្ជាណាមួយទាបជាង ៦០ភាគរយនៃពិន្ទុសរុបជាដាច់ខាត។

**ប្រការ២០.-ខ្លឹមសារមុខវិជ្ជា**

កម្មវិធីនៃមុខជំនាញនីមួយៗ មានគោលបំណង ការពិពណ៌នា និងរចនាសម្ព័ន្ធរួមនៃមុខវិជ្ជានីមួយៗ ព្រមទាំងលទ្ធផលសិក្សាលើចំណេះដឹង ជំនាញក្នុងការគិត ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ និងជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង។

មុខវិជ្ជានីមួយៗនៃកម្មវិធីសិក្សា ត្រូវមានគោលបំណង ការពិពណ៌នាអំពីមុខវិជ្ជា ចំនួនក្រេឌីត និងលទ្ធផលរំពឹងទុក។

## ផ្នែកទី២ ៖ ថ្នាក់បណ្ឌិត

**ប្រការ២១.-រយៈពេលសិក្សា**

១-កម្មវិធីថ្នាក់បណ្ឌិតមានពីរប្រភេទគឺ៖ បណ្ឌិតស្រាវជ្រាវ និង បណ្ឌិតវិជ្ជាជីវៈ។

២-ការសិក្សាថ្នាក់បណ្ឌិតចែកជា៖ ១)ការសិក្សាពេញម៉ោង និង ២)មិនពេញម៉ោង។

ក. និស្សិតសិក្សាពេញម៉ោង គឺជានិស្សិតដែលបានចុះឈ្មោះចូលរៀនគ្រប់មុខវិជ្ជាទាំងអស់នៃឆមាសនីមួយៗ។

ខ. និស្សិតសិក្សាមិនពេញម៉ោង គឺជានិស្សិតដែលបានចុះឈ្មោះចូលរៀនមិនបានគ្រប់មុខវិជ្ជាទាំងអស់នៃឆមាសនីមួយៗ ។

៣-រយៈពេលសិក្សាពីបី (៣) ទៅប្រាំមួយ (៦)ឆ្នាំ សម្រាប់ការសិក្សាពេញម៉ោង និងរហូតដល់ប្រាំបី (៨)ឆ្នាំ សម្រាប់ការសិក្សាមិនពេញម៉ោង។

៤-ចំនួនក្រេឌីតសិក្សាអប្បបរមាសរុបមាន ៥៤ ក្រេឌីត ដោយចែកជាការងារសិក្សាមុខវិជ្ជា និងការងារស្រាវជ្រាវ។

**ប្រការ២២.-កម្មវិធីសិក្សាថ្នាក់បណ្ឌិតស្រាវជ្រាវ**

កម្មវិធីសិក្សាថ្នាក់បណ្ឌិតស្រាវជ្រាវ ត្រូវបានចែកជាតម្លៃអប្បបរមាទៅតាមក្រុមប្រភេទសិក្សាដូចខាងក្រោម ៖

១. ការសិក្សាមុខវិជ្ជា ៖

| | |
|---|---|
| - មុខវិជ្ជាបំពេញបន្ថែម | ៦ ក្រេឌីតសិក្សា |
| - មុខវិជ្ជាកម្រិតបណ្ឌិត | ៦ ក្រេឌីតសិក្សា |
| - មុខវិជ្ជាតម្រង់ទិសនិងការប្រឡងទូទៅ | ៥ ក្រេឌីតសិក្សា |

២. ការសរសេរនិងការពារនិក្ខេបបទ ៖

| | |
|---|---|
| - ការពារគម្រោងស្រាវជ្រាវពិស្តារ | ៣ ក្រេឌីតសិក្សា |
| - ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬអន្តរជាតិ | ៦ ក្រេឌីតសិក្សា |
| - ការចូលរួមវេទិកាវិទ្យាសាស្ត្រដោយមានធ្វើបទបង្ហាញ | ៣ ក្រេឌីតសិក្សា |
| - ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន | ៣ ក្រេឌីតសិក្សា |
| - និក្ខេបបទ | ១៨ ក្រេឌីតសិក្សា |
| **សរុប** | **៥៤ ក្រេឌីតសិក្សា។** |

ការសិក្សាមុខវិជ្ជាតម្រង់ទិសនីមួយៗ មានឈ្មោះមុខវិជ្ជា និងគម្រោងខ្លឹមសារដែលកំណត់ដោយក្រុមមុខជំនាញនីមួយ។

**ប្រការ២៣.-កម្មវិធីសិក្សាថ្នាក់បណ្ឌិតវិជ្ជាជីវៈ**

កម្មវិធីសិក្សាថ្នាក់បណ្ឌិតវិជ្ជាជីវៈ ត្រូវបានចែកជាតម្លៃអប្បបរមាទៅតាមក្រុមប្រភេទសិក្សាដូចខាងក្រោម ៖

១.ការសិក្សាមុខវិជ្ជា ៖

| | |
|---|---|
| - មុខវិជ្ជាបំពេញបន្ថែម | ៦ ក្រេឌីតសិក្សា |
| - មុខវិជ្ជាកម្រិតបណ្ឌិត | ១៥ ក្រេឌីតសិក្សា |
| - សារណាបទពិសោធវិជ្ជាជីវៈ | ៦ ក្រេឌីតសិក្សា |

២. និក្ខេបបទ ៖

- ការពារគម្រោងស្រាវជ្រាវពិស្តារ ៣ ក្រេឌីតសិក្សា
- ការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬអន្តរជាតិ ៦ ក្រេឌីតសិក្សា
- ការចូលរួមវេទិកាវិទ្យាសាស្ត្រដោយមានធ្វើបទបង្ហាញ ៣ ក្រេឌីតសិក្សា
- ការធ្វើសិក្ខាសាលាផ្ទាល់ខ្លួន ៣ ក្រេឌីតសិក្សា
- និក្ខេបបទ ១២ ក្រេឌីតសិក្សា

សរុប ៥៤ ក្រេឌីតសិក្សា។

ការសិក្សាមុខវិជ្ជាតម្រង់ទិសនីមួយៗ មានឈ្មោះមុខវិជ្ជា និងគម្រោងខ្លឹមសារដែលកំណត់ដោយក្រុមមុខជំនាញនីមួយ។

**ប្រការ២៤.-មុខវិជ្ជាបំពេញបន្ថែម**

ការសិក្សាមុខវិជ្ជាបំពេញបន្ថែម ត្រូវធ្វើឡើងនៅដើមឆ្នាំសិក្សាដំបូង។ មុខវិជ្ជាបំពេញបន្ថែមសម្រាប់បេក្ខជនថ្នាក់បណ្ឌិត ត្រូវសម្រេចដោយ អគប តាមសំណើរបស់ក្រុមមុខជំនាញ។

ចាត់ទុកថាទទួលបានជោគជ័យលើគ្រប់មុខវិជ្ជាទាំងអស់ លុះត្រាតែមិនមានមុខវិជ្ជាណាមួយទាបជាង ៧០ភាគរយនៃពិន្ទុសរុបជាដាច់ខាត។

**ប្រការ២៥.-មុខវិជ្ជាកម្រិតបណ្ឌិត**

ការសិក្សាមុខវិជ្ជាកម្រិតបណ្ឌិត ត្រូវមានមុខវិជ្ជារួម និងមុខវិជ្ជាជំនាញដែលត្រូវបានអនុវត្តនៅក្នុងឆ្នាំសិក្សាទី១ និងអាចបន្តទៅឆ្នាំសិក្សាទី២។

**ប្រការ២៦.-ខ្លឹមសារមុខវិជ្ជា**

កម្មវិធីនៃមុខជំនាញនីមួយៗ មានគោលបំណង ការពិពណ៌នា និងរចនាសម្ព័ន្ធរួមនៃមុខវិជ្ជានីមួយៗ ព្រមទាំងលទ្ធផលសិក្សាលើចំណេះដឹង ជំនាញក្នុងការគិត ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ និងជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង។

មុខវិជ្ជានីមួយៗនៃកម្មវិធីសិក្សា ត្រូវមានគោលបំណង ការពិពណ៌នាអំពីមុខវិជ្ជា និងចំនួនក្រេឌីត។

## ផ្នែកទី៣ ៖ ការបង្រៀននិងការវាយតម្លៃលទ្ធផលសិក្សា

**ប្រការ២៧.-ការបង្រៀន**

វិធីសាស្ត្របង្ហាត់បង្រៀនក្នុងពេលសិក្សាតាមមុខវិជ្ជាមាន ៖

- បទឧទ្ទេសនាមក្នុងថ្នាក់ដោយសាស្ត្រាចារ្យ
- ជំរុញនិងលើកទឹកចិត្តឱ្យនិស្សិតស្វ័យសិក្សា
- ជំរុញនិស្សិតឱ្យមានទម្លាប់ស្រាវជ្រាវ ( ប្រាប់ប្រភពនិងឈ្មោះឯកសារពាក់ព័ន្ធ )
- សំណួរត្រួតពិនិត្យ (Quiz)
- កិច្ចការផ្ទះ (Homework)
- ប្រឡងពាក់កណ្តាលឆមាស (Midterm Exam)
- ជំរុញឱ្យនិស្សិតធ្វើកិច្ចការស្រាវជ្រាវ (Assignment, Research Project, Research Report, Term Paper)
- ប្រឡងបញ្ចប់មុខវិជ្ជា (Final Exam)

- ការធ្វើទស្សនកិច្ចសិក្សាខ្លីៗនៅខាងក្រៅសាកលវិទ្យាល័យ
- ការធ្វើសិក្ខាសាលា ឬបាឋកថា ឬសន្និសីទផ្សេងៗ។

**ប្រការ២៨.-ការវាយតម្លៃលទ្ធផលសិក្សា**

រូបមន្តនៃការគណនាមធ្យមភាគតាមមុខវិជ្ជានីមួយៗ

- វត្តមាននិងសកម្មភាពចូលរួមក្នុងពេលសិក្សា (Attendance) ១០%
- ប្រឡងពាក់កណ្ដាលឆមាស (Midterm Exam) ២០%
- កិច្ចការស្រាវជ្រាវ (Assignment) ៣០%
- ប្រឡងបញ្ចប់មុខវិជ្ជាសិក្សា (Final Exam) ៤០%

សរុប ១០០%

**ប្រការ២៩.-ប្រព័ន្ធផ្ដល់ពិន្ទុ និងនិទ្ទេស**

ក. ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| **អត្ថន័យនិទ្ទេស** Meaning | **ពិន្ទុជាភាគរយ** Mark Obtained % | **និទ្ទេសជាអក្សរ** Grade | **ពិន្ទុនិទ្ទេស** Grade Point |
|---|---|---|---|
| ល្អប្រសើរ Excellent | 90-100 | A | 4.00 |
| ល្អណាស់ Very Good | 80-89 | B | 3.50 |
| ល្អ Good | 70-79 | C | 3.00 |
| មធ្យម Fair | 60-69 | D | 2.50 |
| ធ្លាក់ Failed | 50-59 | E | 2.00 |
| អវត្តមាន Incomplete | 0-49 | F | 0.00 |

ខ. ថ្នាក់បណ្ឌិត

| **អត្ថន័យនិទ្ទេស** Meaning | **ពិន្ទុជាភាគរយ** Mark Obtained % | **និទ្ទេសជាអក្សរ** Grade | **ពិន្ទុនិទ្ទេស** Grade Point |
|---|---|---|---|
| ល្អប្រសើរ Excellent | 90-100 | A | 4.00 |
| ល្អណាស់ Very Good | 80-89 | B | 3.50 |
| ល្អ Good | 70-79 | C | 3.00 |
| ធ្លាក់ Failed | 60-69 | D | 2.50 |

| | | | |
|---|---|---|---|
| អវត្តមាន Incomplete | 0-59 | E | 0.00 |

**ប្រការ៣០.-របៀបគណនាភាគមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប**

រូបមន្តគណនាភាគមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (Grade Point Average-GPA) គឺ៖ មធ្យមភាគនៃពិន្ទុនិទ្ទេសសរុប (GPA) ស្មើផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point-P) និង តម្លៃក្រេឌីតដែលត្រូវយកនៃមុខវិជ្ជានីមួយៗ(Attempted Credit Value-C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកគ្រប់មុខវិជ្ជា។

$$GPA = \frac{\Sigma (P \times C)}{\Sigma C}$$

## ជំពូកទី៤
## លក្ខខណ្ឌនិងលក្ខណៈវិនិច្ឆ័យសម្រាប់ការបញ្ចប់ការសិក្សា
### ផ្នែកទី១ ៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

**ប្រការ៣១.-ការរៀបចំយន្តការប្រឡងបញ្ចប់ការសិក្សា**

សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបង្កើតគណៈកម្មការប្រឡងបញ្ចប់ការសិក្សាមួយ ដែលមានសមាសភាពដូចខាងក្រោម៖

- គណៈកម្មការសម្រេចនិងប្រកាសលទ្ធផលចុងក្រោយ
- គណៈមេប្រយោគ។

គណៈកម្មការប្រឡងបញ្ចប់ការសិក្សានេះ មានសិទ្ធិបង្កើតគណៈកម្មការកណ្តាល និងគណៈកម្មការផ្សេងៗទៀតតាមតម្រូវការចាំបាច់ ដើម្បីឱ្យដំណើរការប្រឡងបញ្ចប់ការសិក្សាប្រព្រឹត្តទៅដោយប្រសិទ្ធភាព និងមានតម្លាភាព។

តួនាទីនិងភារកិច្ចគណៈកម្មការកណ្តាល និងគណៈកម្មការផ្សេងៗទៀត ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៣២.-គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃរបាយការណ៍ស្រាវជ្រាវ ឬគម្រោងស្រាវជ្រាវ**

គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃរបាយការណ៍ ឬគម្រោងស្រាវជ្រាវ មានសមាសភាពបី (៣)រូប ដឹកនាំដោយប្រធាន អគប សាស្ត្រាចារ្យណែនាំ ជាសមាជិក និងសមាសភាពមួយ (១)រូបទៀត មានបទពិសោធស្រាវជ្រាវក្នុងមុខជំនាញពាក់ព័ន្ធទៅនឹងប្រធានបទរបាយការណ៍ស្រាវជ្រាវ ឬគម្រោងស្រាវជ្រាវ។

គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃរបាយការណ៍ស្រាវជ្រាវ ឬគម្រោងស្រាវជ្រាវ មានភារកិច្ចទទួលខុសត្រូវលើការណែនាំ ត្រួតពិនិត្យវាយតម្លៃលើវិធីសាស្ត្រនិងខ្លឹមសារ និងចុះហត្ថលេខាលើរបាយការណ៍ស្រាវជ្រាវ ឬគម្រោងស្រាវជ្រាវបញ្ចប់ការសិក្សា។

**ប្រការ៣៣.-ការប្រកាសលទ្ធផលបញ្ចប់ការសិក្សា**

គណៈមេប្រយោគ ត្រូវរៀបចំរបាយការណ៍និងលទ្ធផល ដើម្បីជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យនិងសម្រេច។

**ប្រការ៣៤.-គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃនិក្ខេបបទ**

ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ មានគណៈកម្មការមួយចំនួនដែលបំពេញតួនាទី និងការកិច្ចរៀងៗខ្លួន ដូចខាងក្រោម ៖

ក/ គណៈកម្មការការពារគម្រោងស្រាវជ្រាវពិស្តារ មានសមាសភាពបី (៣)រូប ដឹកនាំដោយប្រធាន អគប សាស្ត្រាចារ្យណែនាំជាសមាជិក និងសមាសភាពមួយ (១)រូបទៀត មានបទពិសោធស្រាវជ្រាវក្នុងមុខជំនាញពាក់ព័ន្ធទៅនឹងប្រធានបទនិក្ខេបបទ។

ខ/ គណៈកម្មការការពារការធ្វើសិក្ខាសាលា មានសមាសភាពបី (៣)រូប ដឹកនាំ ដោយប្រធាន អគប សាស្ត្រាចារ្យណែនាំជាសមាជិក និងសមាសភាពមួយ (១)រូបទៀត មានបទពិសោធស្រាវជ្រាវក្នុងមុខជំនាញពាក់ព័ន្ធទៅនឹងប្រធាន បទនិក្ខេបបទ។

គ/ គណៈកម្មការការពារសាកល្បង មានសមាសភាពបី (៣)រូប ដឹកនាំដោយប្រធាន អគប សាស្ត្រាចារ្យណែនាំជាសមាជិក និងសមាសភាពមួយ (១)រូបទៀត មានបទពិសោធស្រាវជ្រាវក្នុងមុខជំនាញពាក់ព័ន្ធទៅនឹងប្រធានបទ និក្ខេបបទ។

ឃ/គណៈកម្មការការពារបញ្ចប់មានសមាសភាពប្រាំ (៥)រូប មានប្រធានមួយ (១)រូប លេខាវិទ្យាសាស្ត្រមួយ (១)រូប គណៈកម្មការវាយតម្លៃនិក្ខេបបទឯករាជ្យពីរ (២)រូប និងសាស្ត្រាចារ្យណែនាំមួយ (១)រូប។ សមាសភាពគណៈកម្មការ នេះ ត្រូវសម្រេចដោយក្រសួងអប់រំ យុវជន និងកីឡា តាមការស្នើសុំរបស់សាកលវិទ្យាល័យ។

ង/ គណៈកម្មការដោះស្រាយទំនាស់ មានការកិច្ចដោះស្រាយទំនាស់ការសិក្សា និងវិទ្យាសាស្ត្ររបស់និស្សិត និងសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - សាកលវិទ្យាធិការ ឬតំណាង | ប្រធាន |
| - ប្រធាន អគប | អនុប្រធានអចិន្ត្រៃយ៍ |
| - ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាវិទ្យាសាស្ត្រ | អនុប្រធាន |
| - ប្រធានផ្នែកគ្រប់គ្រងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | សមាជិក |
| - ប្រធានផ្នែករដ្ឋបាលសិក្សា | សមាជិក |
| - សាស្ត្រាចារ្យណែនាំរបស់សាមីនិស្សិត | សមាជិក |
| - ប្រធានផ្នែកគ្រប់គ្រងការស្រាវជ្រាវនិងនិក្ខេបបទ | លេខាធិការ។ |

**ប្រការ៣៥.-ការរៀបចំនិក្ខេបបទ**

និក្ខេបបទ ដែលត្រូវសរសេរទៅតាមជំនាញនីមួយៗ ត្រូវឱ្យមានលក្ខណៈវិទ្យាសាស្ត្រ តាមស្តង់ដាជាតិនិងអន្តរជាតិ។ និក្ខេបបទនេះ ត្រូវមានទម្រង់គំរូមួយ ដែលមានការណែនាំដោយឡែករបស់សាកលវិទ្យាល័យ និងត្រូវចម្លងជូនទៅក្រសួងអប់រំ យុវជន និងកីឡា។

ប្រធានបទនិក្ខេបបទ ដែលជ្រើសរើសឡើងត្រូវមានការឯកភាពគ្នានិងចុះហត្ថលេខារវាងសាមីនិស្សិត សាស្ត្រាចារ្យណែនាំ និងអគប។

**ប្រការ៣៦.-ការវាយតម្លៃនិក្ខេបបទ**

ការវាយតម្លៃនិក្ខេបបទត្រូវធ្វើឡើងជាបន្តបន្ទាប់តាមលំដាប់លំដោយដូចខាងក្រោម ៖

- ការវាយតម្លៃគម្រោងស្រាវជ្រាវពិស្តារ
- ការវាយតម្លៃនិក្ខេបបទសាកល្បង
- ការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ការសិក្សា។

**ប្រការ៣៧.-ការវាយតម្លៃគម្រោងស្រាវជ្រាវពិស្តារ**

និស្សិតត្រូវការពារគម្រោងស្រាវជ្រាវពិស្តារជាផ្លូវការនិងជាសាធារណៈ នៅចំពោះមុខ គណៈកម្មការដែលផ្អែកតាមសំណើសុំរបស់សាមីខ្លួន និងមានការយល់ព្រមពីសាស្ត្រាចារ្យណែនាំ ដោយមានការឯកភាពពីសាកលវិទ្យាល័យ។

**ប្រការ៣៨.-ការការពារនិក្ខេបបទសាកល្បង**

និស្សិតត្រូវការពារនិក្ខេបបទសាកល្បងជាផ្លូវការនិងជាសាធារណៈ នៅចំពោះមុខគណៈកម្មការ ដែលផ្អែកតាមសំណើសុំរបស់សាមីខ្លួន និងមានការយល់ព្រមពីសាស្ត្រាចារ្យណែនាំ ដោយមានការឯកភាពពីសាកលវិទ្យាល័យ។

**ប្រការ៣៩.-ការការពារនិក្ខេបបទបញ្ចប់ការសិក្សា**

សាកលវិទ្យាល័យ នឹងត្រូវបញ្ជូនសំណុំលិខិតរបស់និស្សិតទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំការពារនិក្ខេបបទបញ្ចប់។

និស្សិតត្រូវការពារនិក្ខេបបទបញ្ចប់ជាផ្លូវការនិងជាសាធារណៈ នៅចំពោះមុខគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ ដែលស្នើឡើងដោយសាកលវិទ្យាល័យ និងមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤០.-ការការពារនិក្ខេបបទឡើងវិញ**

និស្សិតដែលពុំទទួលបានជោគជ័យក្នុងការការពារនិក្ខេបបទបញ្ចប់ ត្រូវបានអនុញ្ញាតឱ្យការពារនិក្ខេបបទឡើងវិញ តាមលក្ខខណ្ឌដូចខាងក្រោម ៖

- និស្សិតត្រូវកែសម្រួលនិក្ខេបបទឡើងវិញ ហើយដាក់ស្នើសុំការពារជាលើកទីពីរយ៉ាងយូរបំផុតត្រឹម ៦ខែ គិតចាប់ពីថ្ងៃដែលបានការពារលើកទីមួយ
- សមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទឡើងវិញ ត្រូវដូចគ្នាទៅនឹងសមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ដែរ។ ករណីមានសមាជិកគណៈកម្មការណាមួយអវត្តមាន សាកលវិទ្យាល័យនឹងស្នើឈ្មោះសុំមកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបំពេញជំនួស
- មិនអនុញ្ញាតឱ្យការពារនិក្ខេបបទជាលើកទីបីឡើយ។

**ប្រការ៤១.-លក្ខខណ្ឌសម្រាប់អនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់**

និស្សិតត្រូវបំពេញគ្រប់លក្ខខណ្ឌ ដើម្បីទទួលបានការអនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់ដូចខាងក្រោម ៖

- និស្សិតត្រូវប្រគល់និក្ខេបបទសម្រាប់ការវាយតម្លៃ
- និក្ខេបបទត្រូវបានឯកភាពពីសាស្ត្រាចារ្យណែនាំ និងគាំទ្រដោយគណៈកម្មការវាយតម្លៃឯកភាពជាដោយសម្លេងភាគច្រើន។

**ប្រការ៤២.-ការបញ្ជូនលទ្ធផលបញ្ចប់**

បន្ទាប់ពីការការពារនិក្ខេបបទបញ្ចប់ និស្សិតត្រូវបញ្ជូនរបាយការណ៍និងនិក្ខេបបទ ស្តីពីការកែលម្អ មក អគប យ៉ាងយូរ ២០(ម្ភៃ)ថ្ងៃ ដើម្បីសាកលវិទ្យាល័យបញ្ជូនរបាយការណ៍ស្តីពីការការពារនិក្ខេបបទបញ្ចប់ទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី២ ៖ ថ្នាក់បណ្ឌិត

**ប្រការ៤៣.-គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃនិក្ខេបបទ**

ការបណ្តុះបណ្តាលថ្នាក់បណ្ឌិតនេះ មានគណៈកម្មការមួយចំនួនដូចខាងក្រោមដែលបំពេញតួនាទីនិងភារកិច្ចរៀងៗខ្លួន៖

ក/ គណៈកម្មការការពារគម្រោងពិស្តារ មានសមាសភាពប្រាំពីរ (៧)រូប មានប្រធានមួយ (១)រូប លេខាវិទ្យាសាស្ត្រមួយ (១)រូប គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ្យបី (៣)រូប សាស្ត្រាចារ្យណែនាំគោលមួយ (១)រូប និងសាស្ត្រាចារ្យណែនាំរងមួយ (១)រូប ជាសមាជិកនៃគណៈកម្មការនេះ។

ខ/ គណៈកម្មការការពារនិក្ខេបបទសាកល្បង មានសមាសភាពប្រាំពីរ(៧)រូប មានប្រធានមួយ (១)រូប លេខាវិទ្យាសាស្ត្រមួយ (១)រូប គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ្យបី (៣)រូប សាស្ត្រាចារ្យណែនាំគោលមួយ (១)រូប និងសាស្ត្រាចារ្យណែនាំរងមួយ (១)រូប ជាសមាជិកនៃគណៈកម្មការនេះ។

គ/ គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ្យ មានសមាសភាពចំនួនបី (៣)រូប មួយ (១)រូប ជាអ្នកវាយតម្លៃរបស់គ្រឹះស្ថានឧត្តមសិក្សា និងពីរ (២)រូបទៀត ជាអ្នកវាយតម្លៃមកពីខាងក្រៅ។

ឃ/គណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ មានសមាសភាពប្រាំពីរ(៧)រូប មានប្រធានមួយ (១)រូប លេខាវិទ្យាសាស្ត្រមួយ (១)រូប គណៈកម្មការពិនិត្យនិងវាយតម្លៃនិក្ខេបបទឯករាជ្យបី (៣)រូប សាស្ត្រាចារ្យណែនាំគោលមួយ (១)រូប និងសាស្ត្រាចារ្យណែនាំរងមួយ (១)រូប ជាសមាជិកនៃគណៈកម្មការនេះ។ សមាសភាពគណៈកម្មការនេះ ត្រូវសម្រេចដោយក្រសួងអប់រំ យុវជន និងកីឡា តាមការស្នើសុំរបស់សាកលវិទ្យាល័យ។

ង/ គណៈកម្មការដោះស្រាយទំនាស់ មានភារកិច្ចដោះស្រាយទំនាស់ការសិក្សា និងវិទ្យាសាស្ត្ររបស់និស្សិត និងសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| - សាកលវិទ្យាធិការ ឬតំណាង | ប្រធាន |
| - ប្រធាន អគប | អនុប្រធានអចិន្ត្រៃយ៍ |
| - ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាវិទ្យាសាស្ត្រ | អនុប្រធាន |
| - ប្រធានផ្នែកគ្រប់គ្រងថ្នាក់បណ្ឌិត | សមាជិក |
| - ប្រធានផ្នែករដ្ឋបាលសិក្សា | សមាជិក |
| - សាស្ត្រាចារ្យណែនាំគោលរបស់សាមីនិស្សិត | សមាជិក |
| - ប្រធានផ្នែកគ្រប់គ្រងការស្រាវជ្រាវនិងនិក្ខេបបទ | លេខាធិការ |

**ប្រការ៤៤.-ការរៀបចំនិក្ខេបបទបណ្ឌិត**

និក្ខេបបទ ដែលត្រូវសរសេរទៅតាមជំនាញនីមួយៗនិងត្រូវឱ្យមានលក្ខណៈវិទ្យាសាស្ត្រ តាមស្តង់ដាជាតិនិងអន្តរជាតិ។ និក្ខេបបទនេះ ត្រូវមានទម្រង់គំរូរួមមួយ ដែលមានការណែនាំដោយឡែកពីសាកលវិទ្យាល័យ និងត្រូវចម្លងជូនទៅក្រសួងអប់រំ យុវជន និងកីឡា។

ប្រធានបទនិក្ខេបបទ ដែលជ្រើសរើសឡើងត្រូវមានការឯកភាពគ្នានិងចុះហត្ថលេខារវាងសាមីនិស្សិត សាស្ត្រាចារ្យណែនាំ និងអគប។

**ប្រការ៤៥.-ការវាយតម្លៃនិក្ខេបបទ**

ការវាយតម្លៃនិក្ខេបបទត្រូវធ្វើឡើងបុន្តបន្ទាប់តាមលំដាប់លំដោយដូចខាងក្រោម ៖

- ការវាយតម្លៃគម្រោងស្រាវជ្រាវពិស្តារ
- ការវាយតម្លៃនិក្ខេបបទសាកល្បង
- ការវាយតម្លៃនិក្ខេបបទដោយគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ្យ ការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់។

**ប្រការ៤៦.-ការវាយតម្លៃគម្រោងស្រាវជ្រាវពិស្តារ**

និស្សិតត្រូវការពារគម្រោងស្រាវជ្រាវពិស្តារជាផ្លូវការនិងជាសាធារណៈ នៅចំពោះមុខ គណៈកម្មការ ដែលផ្អែកតាមសំណើសុំរបស់សាមីខ្លួន និងមានការយល់ព្រមពីសាស្ត្រាចារ្យណែនាំ ដោយមានការឯកភាពពីសាកលវិទ្យាល័យ។

**ប្រការ៤៧.-ការការពារនិក្ខេបបទសាកល្បង**

និស្សិតត្រូវការពារនិក្ខេបបទសាកល្បងជាផ្លូវការនិងជាសាធារណៈ នៅចំពោះមុខគណៈកម្មការ ដែលផ្អែកតាមសំណើសុំរបស់សាមីខ្លួន និងមានការយល់ព្រមពីសាស្ត្រាចារ្យណែនាំ ដោយមានការឯកភាពពីសាកលវិទ្យាល័យ។

**ប្រការ៤៨.-ការការពារនិក្ខេបបទបញ្ចប់ការសិក្សា**

សាកលវិទ្យាល័យ នឹងត្រូវបញ្ជូនសំណុំលិខិតរបស់និស្សិតទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំការពារនិក្ខេបបទបញ្ចប់។

និស្សិតត្រូវការពារនិក្ខេបបទបញ្ចប់ជាផ្លូវការនិងជាសាធារណៈ នៅចំពោះមុខគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ ដែលស្នើឡើងដោយសាកលវិទ្យាល័យ និងមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤៩.-ការការពារនិក្ខេបបទឡើងវិញ**

បេក្ខជនបណ្ឌិត ដែលពុំទទួលបានជោគជ័យក្នុងការការពារនិក្ខេបបទបញ្ចប់ត្រូវបានអនុញ្ញាតឱ្យការពារនិក្ខេបបទឡើងវិញ តាមលក្ខខណ្ឌដូចខាងក្រោម ៖

- បេក្ខជនបណ្ឌិតត្រូវកែសម្រួលនិក្ខេបបទឡើងវិញ ហើយដាក់ស្នើសុំការពារជាលើកទីពីរ យ៉ាងយូរបំផុតត្រឹម ២៤ខែ គិតចាប់ពីថ្ងៃដែលបានការពារលើកទីមួយ
- សមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទឡើងវិញ ត្រូវដូចគ្នាទៅនឹងសមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទឡើងវិញ ត្រូវដូចគ្នាទៅនឹងសមាសគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ដែរ។ ករណីមានសមាជិកគណៈកម្មការណាមួយអវត្តមាន សាកលវិទ្យាល័យនឹងស្នើឈ្មោះសុំមកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបំពេញជំនួស
- មិនអនុញ្ញាតឱ្យការពារនិក្ខេបបទជាលើកទីបីឡើយ។

**ប្រការ៥០.-លក្ខខណ្ឌសម្រាប់អនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់**

និស្សិតត្រូវបំពេញគ្រប់លក្ខខណ្ឌ ដើម្បីទទួលបានការអនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់ដូចខាងក្រោម ៖

- និស្សិតត្រូវប្រគល់និក្ខេបបទសម្រាប់ការវាយតម្លៃ
- និក្ខេបបទត្រូវបានឯកភាពពីសាស្ត្រាចារ្យណែនាំ និងគាំទ្រដោយគណៈកម្មការវាយតម្លៃឯកភាពដោយសម្លេងភាគច្រើន។

**ប្រការ៥១.-ការបញ្ជូនលទ្ធផលបញ្ចប់**

បន្ទាប់ពីការការពារនិក្ខេបបទបញ្ចប់ និស្សិតត្រូវបញ្ជូនរបាយការណ៍និងនិក្ខេបបទ ស្តីពីការកែលម្អ មក អគប យ៉ាងយូរ ២០(ម្ភៃ)ថ្ងៃ ដើម្បីសាកលវិទ្យាល័យបញ្ជូនរបាយការណ៍ស្តីពីការការពារនិក្ខេបបទបញ្ចប់ទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងសម្រេច។

## ជំពូកទី៥
## វិន័យនិងសីលធម៌

**ប្រការ៥២.-ការបង់ថ្លៃសិក្សា**

និស្សិតគ្រប់រូបត្រូវបង់ថ្លៃសិក្សាជាមុនរៀងរាល់ដើមឆ្នាំសិក្សា ឬឆមាសនីមួយៗ។ ប្រាក់ដែលបានបង់ថ្លៃសិក្សារួចហើយមិនអាចដកវិញបានទេ។

**ប្រការ៥៣.-ឯកសណ្ឋាននិស្សិត**

និស្សិតត្រូវស្លៀកពាក់ឯកសណ្ឋាន ដែលកំណត់ដោយសាកលវិទ្យាល័យដូចខាងក្រោម ៖

ក/ និស្សិតប្រុស ៖ ខោជើងវែងពណ៌ទឹកប៊ិចចាស់/ខ្មៅ និងអាវពណ៌ *សលាត ស្បែកជើងឃ្លុប* ហើយត្រូវដាក់អាវក្នុងខោ និងត្រូវមានកាតសម្គាល់ខ្លួនជាដាច់ខាត។

ខ/ និស្សិតស្រី ៖ សំពត់ពណ៌ទឹកប៊ិចចាស់/ខ្មៅ ត្រឹមជង្គង់ និងអាវពណ៌ *សលាត ស្បែកជើងឃ្លុប ឬក្រវ៉ាត់កែង* ហើយត្រូវដាក់អាវក្នុងសំពត់ និងត្រូវមានកាតសម្គាល់ខ្លួនជាដាច់ខាត។

គ/ និស្សិតពេលយប់ ឬចុងសប្តាហ៍ត្រូវស្លៀកពាក់សមរម្យនិងថ្លៃថ្នូរ។

- ហាមពាក់អាវយឺតអត់ក
- ហាមស្លៀកខោជើងខ្លី
- ត្រូវដាក់អាវក្នុងខោ ឬសំពត់។

**ប្រការ៥៤.-អំពីការសិក្សា**

និស្សិតត្រូវអនុវត្តតាមកាលវិភាគ និងកម្មវិធីសិក្សាដែលបានកំណត់ដោយសាកលវិទ្យាល័យ។ និស្សិតទាំងអស់ត្រូវមករៀនឲ្យបានទាន់ពេលវេលា។ករណីសុំប្តូរពេលសិក្សា ត្រូវមានការសម្រេចដោយ អគប។

**ប្រការ៥៥.-ការព្យួរការសិក្សា**

និស្សិតគ្រប់រូបអាចព្យួរការសិក្សាបានលុះត្រាតែ ៖

- បង់ថ្លៃសេវារដ្ឋបាល ៥០ (ហាសិប) ដុល្លាអាមេរិក ក្នុងមួយឆមាស មុនចាប់ផ្តើមវគ្គថ្មី
- ក្រោយពីចាប់ផ្តើមវគ្គថ្មីបានមួយ (១)ខែ និស្សិតអាចព្យួរការសិក្សាបាន ប៉ុន្តែត្រូវបង់ថ្លៃសិក្សាឡើងវិញ នៅពេលចូលរៀនបន្ត
- មិនអាចដកប្រាក់ថ្លៃសិក្សាវិញបានឡើយ។

- និស្សិតមិនអាចព្យួរការសិក្សាក្នុងរយៈពេលពីរឆ្នាំជាប់គ្នាបានទេ ក្នុងរយៈពេលសិក្សារហូតដល់ឆ្នាំបញ្ចប់ការសិក្សា។

ពេលសុំចូលរៀនវិញ និស្សិតត្រូវមកដាក់ពាក្យសុំចូលរៀនឲ្យបានមួយខែមុនពេលផុតកំណត់ នៃរយៈពេលព្យួរការសិក្សា។ ប្រសិនបើនិស្សិតរូបណាពុំបានមកដាក់ពាក្យសុំចូលរៀនតាមកាលកំណត់ សាកលវិទ្យាល័យចាត់ទុកថា និស្សិតរូបនោះបានបោះបង់ការសិក្សារបស់ខ្លួន។

**ប្រការ៥៦.-អំពីសីលធម៌**

ក/ សីលធម៌ក្នុងថ្នាក់រៀន ៖

- និស្សិតត្រូវគោរពពេលវេលាតាមកាលវិភាគរបស់សាកលវិទ្យាល័យឲ្យបានម៉ឺងម៉ាត់។ ករណីមកយឺត លើសពីដប់ប្រាំ (១៥)នាទី មិនអនុញ្ញាតឲ្យចូលរៀនឡើយ។ លើកលែងមានការអនុញ្ញាតពី អគប នៃសាកលវិទ្យាល័យ
- ពេលម៉ោងសិក្សា និស្សិតត្រូវយកចិត្តទុកដាក់រៀនសូត្រប្រកបដោយសណ្ដាប់ធ្នាប់ និងមានរបៀបរៀបរយ
- ពេលសាស្ត្រាចារ្យ ឬភ្ញៀវអញ្ជើញចូលក្នុងថ្នាក់រៀន និស្សិតទាំងអស់ត្រូវរក្សាភាពស្ងៀមស្ងាត់ និងសម្ដែងនូវអាកប្បកិរិយាថ្លៃថ្នូរ
- ពេលសាស្ត្រាចារ្យអវត្តមាន ឬមកយឺតរយៈពេលលើសពីដប់ប្រាំ (១៥)នាទី និស្សិតក្នុងថ្នាក់ត្រូវរក្សាភាពស្ងៀមស្ងាត់ ហើយប្រធាន អនុប្រធានថ្នាក់ ឬតំណាងនិស្សិតម្នាក់មកទំនាក់ទំនងនិងទទួលព័ត៌មានពី អគប
- ពេលចេញក្រៅថ្នាក់ ឬចេញទៅផ្ទះមុនម៉ោង ដោយមានធុរៈចាំបាច់ ឬមានជំងឺផ្ទាល់ខ្លួន និស្សិតត្រូវសុំអនុញ្ញាតពីសាស្ត្រាចារ្យដែលកំពុងបង្រៀន
- ក្នុងពេលកំពុងសិក្សា និស្សិតមិនត្រូវនាំមិត្តភក្តិ ឬសាច់ញាតិពីខាងក្រៅមកចូលអង្គុយក្នុងថ្នាក់របស់ខ្លួនឡើយ។

ខ/ សីលធម៌ក្នុងបរិវេណសាកលវិទ្យាល័យនិស្សិតទាំងអស់មិនត្រូវ ៖

- ជក់បារី សេពគ្រឿងស្រវឹង និងប្រើប្រាស់ ឬជួញដូរគ្រឿងញៀនជាដាច់ខាត
- យកអាវុធជាតិផ្ទុះគ្រប់ប្រភេទ គ្រឿងញៀន គ្រឿងស្រវឹង ចូលមកក្នុងបរិវេណសាកលវិទ្យាល័យឡើយ
- លេងល្បែងស៊ីសង ឬប្រព្រឹត្តអំពើពាលាដែលខុសច្បាប់និងប្រពៃណីជាតិ
- ធ្វើសកម្មភាពទាំងឡាយណាដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស និងផលប្រយោជន៍របស់សាកលវិទ្យាល័យ និងសង្គមជាតិ។
- ស្រែកឡូឡា ឬប្រើពាក្យអាសអាភាស អាសគ្រាម និងអាកប្បកិរិយាមិនថ្លៃថ្នូរដែលប្រាសចាកពីប្រពៃណីជាតិ
- ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសាកលវិទ្យាល័យ ដោយប្រការណាមួយឡើយ។

**ប្រការ៥៧.-ករណីអវត្តមាន ឥតច្បាប់**

ក/ ការឈប់ឥតច្បាប់ចំនួនប្រាំ (៥)ដង ក្នុងមុខវិជ្ជាតែមួយ នឹងត្រូវទទួលការព្រមានដោយក្រុមប្រឹក្សាវិន័យ។

ខ/ ការឈប់ឥតច្បាប់ចំនួនដប់ (១០)ដង ក្នុងមុខវិជ្ជាណាមួយត្រូវធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ហើយរង់ចាំប្រឡងសងឡើងវិញតាមកាលបរិច្ឆេទកំណត់របស់សាកលវិទ្យាល័យ។

**ប្រការ៥៨.-ករណីអវត្តមាន មានច្បាប់**

ក/ និស្សិតត្រូវសុំច្បាប់ជាមុននៅ អគប ដោយបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់។

ខ/ ការឈប់មានច្បាប់ចំនួនដប់ (១០)ដង ក្នុងមុខវិជ្ជាណាមួយ នឹងត្រូវទទួលការព្រមានដោយក្រុមប្រឹក្សាវិន័យ។

គ/ ការឈប់មានច្បាប់ចំនួនដប់ប្រាំ (១៥)ដង ក្នុងមុខវិជ្ជាណាមួយ ត្រូវកំណត់ថាធ្លាក់លើមុខវិជ្ជានោះដោយស្វ័យប្រវត្តិ ហើយត្រូវរង់ចាំការប្រឡងសងឡើងវិញទៅតាមកាលបរិច្ឆេទដែលកំណត់ដោយសាកលវិទ្យាល័យ។

**ប្រការ៥៩.-ការប្រឡង**

នៅពេលប្រឡងនិស្សិតគ្រប់រូបត្រូវគោរពបទបញ្ជាផ្ទៃក្នុង និងសេចក្តីណែនាំនានា របស់សាកលវិទ្យាល័យ ដូចខាងក្រោម៖

ក/ អង្គុយតាមលេខតុដែលកំណត់ដោយគណៈកម្មការប្រឡង។

ខ/ បំពេញក្បាលសន្លឹកកិច្ចការឱ្យបានគ្រប់ចំណុចតាមការណែនាំរបស់គណៈកម្មការប្រឡង។ ករណីនិស្សិតមិនបានបំពេញក្បាលសន្លឹកកិច្ចការនោះត្រូវបានពិន្ទុសូន្យ។

គ/ ចុះហត្ថលេខាលើបញ្ជីវត្តមានប្រឡង។

ឃ/ ប្រើប្រាស់ទឹកប៊ិចពណ៌ខៀវ ករណីផ្ទុយត្រូវមានការអនុញ្ញាតពីអនុរក្ស។

ង/ រក្សាភាពស្ងៀមស្ងាត់ អង្គុយឱ្យបានសមរម្យ។

ច/ ហាមងាកសួរអ្នកជិតខាង។

ឆ/ ហាមចេញក្រៅបន្ទប់ក្នុងពេលប្រឡង លើកលែងតែមានការអនុញ្ញាតពីអនុរក្ស។

ជ/ ហាមយកសំណៅឯកសារផ្សេងៗចូលក្នុងបន្ទប់ប្រឡង លើកលែងតែមានការអនុញ្ញាតពីគណៈកម្មការប្រឡង។

ឈ/ហាមប្រើប្រាស់ទូរសព្ទ ឬវិទ្យុទាក់ទង។

ញ/ ត្រូវអនុវត្តតាមការណែនាំរបស់គណៈកម្មការត្រួតពិនិត្យ និងអនុរក្ស។

ដ/ នៅពេលចប់ម៉ោង និស្សិតត្រូវប្រគល់សន្លឹកកិច្ចការទៅឱ្យអនុរក្ស ទោះបីជាសន្លឹកកិច្ចការនោះគ្មានសរសេរចម្លើយក៏ដោយ។

ឋ/ មិនអនុញ្ញាតឱ្យចូលប្រឡងក្នុងករណី ៖

- មកយឺតលើសពីដប់ប្រាំ (១៥) នាទី
- មានយកអាវុធជាតិផ្ទុះមកជាមួយ
- ប្រើប្រាស់ទឹកលុប
- គ្មានកាត ឬបណ្ណសម្គាល់ខ្លួននិស្សិត
- គ្មានបង្កាន់ដៃបង់ប្រាក់ ក្នុងករណីប្រឡងសង។

**ប្រការ៦០.-ករណីកំហុសក្នុងពេលប្រឡង**

ក/ មានឯកសារ ឬសំណៅផ្សេងៗនៅពេលប្រឡង ៖

- ត្រូវទទួលការព្រមានដោយដក ៥ពិន្ទុ ក្នុងករណីចាប់បានលើកទី១
- ត្រូវទទួលការព្រមានដោយដក ១០ពិន្ទុ ក្នុងករណីចាប់បានលើកទី២
- បញ្ឈប់ការប្រឡងលើមុខវិជ្ជានោះ ក្នុងករណីចាប់បានលើកទី៣។

ខ/ បោះសំណៅឯកសារទៅឲ្យមិត្តភក្តិ ៖

- ត្រូវទទួលការព្រមានដោយដក ៥ពិន្ទុ ក្នុងករណីចាប់បានលើកទី១
- ត្រូវទទួលការព្រមានដោយដក ១០ពិន្ទុ ក្នុងករណីចាប់បានលើកទី២
- បញ្ឈប់ការប្រឡងលើមុខវិជ្ជានោះ ក្នុងករណីចាប់បានលើកទី៣។

គ/ ដក ៥ពិន្ទុ ករណីអង្គុយខុសលេខតុរបស់ខ្លួន និងបញ្ឈប់ពីការប្រឡងក្នុងករណីមិនគោរព តាមការណែនាំរបស់អនុរក្ស។

ឃ/ត្រូវបានពិន្ទុសូន្យ ក្នុងករណីនិស្សិតមិនបានប្រគល់សន្លឹកកិច្ចការដល់អនុរក្ស នៅពេលបញ្ចប់ការប្រឡង។

ង/ ត្រូវបានពិន្ទុសូន្យ ក្នុងករណីនិស្សិតលួចមើលសំណៅឯកសារក្រៅបន្ទប់ប្រឡង។

ច/ ត្រូវបានពិន្ទុសូន្យ ក្នុងករណីនិស្សិតមិនបានចុះហត្ថលេខាលើបញ្ជីវត្តមានប្រឡង។

ឆ/ ត្រូវបញ្ឈប់ពីការប្រឡងជាបន្ទាន់ និងបញ្ជូនទៅក្រុមប្រឹក្សាវិន័យដើម្បីវិនិច្ឆ័យករណីនិស្សិតដែលសម្តែងអាកប្បកិរិយាមិនសមរម្យ ប្រើពាក្យសំដីមិនថ្លៃថ្នូរ និងស្រែកឡូឡា ដែលនាំឲ្យរំខានក្នុងពេលប្រឡង។

ជ/ ករណីបង្កទំនាស់ជាមួយគណៈកម្មការប្រឡង ត្រូវទទួលពិន័យចាប់ពីបញ្ឈប់ការប្រឡង រហូតដល់បណ្តេញចេញពីសាកលវិទ្យាល័យជាស្ថាពរ ដោយផ្អែកទៅលើទំហំនៃអំពើប្រព្រឹត្តជាក់ស្តែងដែលបានបង្កឡើង។

ឈ/ ករណីហែកចោលសន្លឹកកិច្ចការប្រឡង ៖
- បញ្ឈប់ពីការប្រឡងគ្រប់មុខវិជ្ជាទាំងអស់ ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តទៅ។
- ការប្រព្រឹត្តក្នុងករណីដដែលជាលើកទី២ ទៀត ត្រូវលុបឈ្មោះចេញពីបញ្ជីនិស្សិត នៃសាកលវិទ្យាល័យ ជាស្ថាពរដោយគ្មានលក្ខខណ្ឌ និងបិទផ្សាយជាសាធារណៈ។

៣/ករណីនិស្សិតប្រឡងជំនួស ឬប្រឡងជួយនិស្សិតម្នាក់ទៀត និស្សិតទាំងពីរនេះត្រូវទទួលពិន័យពីក្រុមប្រឹក្សាវិន័យ ចាប់ពីការបញ្ឈប់ការប្រឡងគ្រប់មុខវិជ្ជាទាំងអស់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តទៅរហូតដល់បណ្តេញចេញពីសាកលវិទ្យាល័យជាស្ថាពរដោយគ្មានលក្ខខណ្ឌ។

## ជំពូកទី៦
## សិល្បៈ វប្បធម៌ កីឡា សហគមន៍ និងការចូលរួមក្នុងកម្មវិធីផ្សេងៗ

### ប្រការ៦១.-អំពីសិល្បៈ វប្បធម៌ និងសហគមន៍

និស្សិតអាចចូលរួមក្នុងសកម្មភាពសិល្បៈ វប្បធម៌ សហគមន៍ ដែលរៀបចំឡើងដោយសាកលវិទ្យាល័យ ដើម្បីចូលរួមចំណែកលើកស្ទួយនិងអភិរក្សសិល្បៈ វប្បធម៌ និងប្រពៃណីជាតិ ព្រមទាំងការងារសហគមន៍។

### ប្រការ៦២.-អំពីកីឡា

និស្សិតអាចចូលរួមក្នុងសកម្មភាពកីឡា ដែលរៀបចំដោយសាកលវិទ្យាល័យ និងអាចចូលរួមក្នុងការប្រកួតប្រជែងជ្រើសរើសជើងឯកប្រចាំសាកលវិទ្យាល័យ និងថ្នាក់ជាតិ។

**ប្រការ៦៣.-សេវាសុខភាព**

និស្សិតដែលមានជំងឺអាចមកពិគ្រោះនិងព្យាបាលជំងឺនៅមន្ទីរពេហុព្យាបាលនិងសម្ពតអង្គរធំដែលជាដៃគូរបស់សាកលវិទ្យាល័យ ដោយទទួលបានការបញ្ចុះតម្លៃ ៥ភាគរយ។ ដោយឡែក ចំពោះការពិគ្រោះនិងព្យាបាលជំងឺមាត់ធ្មេញ ត្រូវទៅមន្ទីរពេទ្យហង្សនាគដោយទទួលបានការបញ្ចុះតម្លៃ ៥ភាគរយ។

និស្សិតដែលមានជំងឺឆ្លង ឬមានជំងឺធ្ងន់ធ្ងរជាប្រចាំ ត្រូវអនុញ្ញាតច្បាប់ឈប់សម្រាកតាមវេជ្ជបញ្ជា ឬការណែនាំរបស់គ្រូពេទ្យ។

ករណីនិស្សិតមានបញ្ហាគ្រោះថ្នាក់ផ្សេងៗ (លើកលែងបញ្ហាសុខភាព) ក្នុងរយៈពេល ២៤ម៉ោង ៧ថ្ងៃក្នុងមួយសប្តាហ៍ សូមទំនាក់ទំនងមកលោក សេង វិសាល ទូរសព្ទលេខ៖ ០៨១ ៤៥២ ២១៣ ឬ ០៨៨ ៦៨១ ៦៩ ៦៩ ដើម្បីទទួលបានសេវាធានារ៉ាប់រងគ្រោះថ្នាក់។

**ប្រការ៦៤.-ការចូលរួមកម្មវិធីផ្សេងៗ**

និស្សិតត្រូវចូលរួមក្នុងកម្មវិធីផ្សេងៗ ដែលរៀបចំដោយសាកលវិទ្យាល័យដូចជា ៖

- ការប្រគល់សញ្ញាបត្រ
- ការតាំងពិព័រណ៍ប្រចាំឆ្នាំ
- ការចុះទស្សនកិច្ចសិក្សា
- សិក្ខាសាលា បាឋកថា សន្និសីទ
- ការការពារនិក្ខេបបទ
- Alumni
- ការប្រជុំផ្សព្វផ្សាយផែនការផ្សេងៗ
- ការចែករង្វាន់លើកទឹកចិត្តដល់និស្សិតឆ្នើម។ល។

រាល់កម្មវិធីនានា ដែលរៀបចំដោយនិស្សិតនៅក្នុងសាកលវិទ្យាល័យត្រូវបានស្វាគមន៍ ប៉ុន្តែត្រូវមានការអនុញ្ញាតជាមុនពីគណៈគ្រប់គ្រងសាកលវិទ្យាល័យ។

## ជំពូកទី៧
## វិធានការរដ្ឋបាល និងការលើកទឹកចិត្ត

**ប្រការ៦៥.-វិធានការរដ្ឋបាល**

និស្សិតដែលប្រព្រឹត្តខុសនឹងវិន័យរបស់សាកលវិទ្យាល័យ នឹងត្រូវទទួលពិន័យ ដូចខាងក្រោម ៖

- ការណែនាំដោយផ្ទាល់មាត់
- ការព្រមានជាលាយលក្ខណ៍អក្សរ
- បិទប្រកាសផ្សាយជាសាធារណៈនៅក្នុងបរិវេណសាកលវិទ្យាល័យ
- ឱ្យបង់សំណងជាប្រាក់ទៅតាមទំហំនៃការខូចខាតសម្ភារៈរបស់សាកលវិទ្យាល័យ
- ចារឹកក្នុងឯកសារវាយតម្លៃរបស់និស្សិតនៃសាកលវិទ្យាល័យ
- ព្យួរការសិក្សា
- បញ្ឈប់ការសិក្សាជាស្ថាពរពីសាកលវិទ្យាល័យដោយគ្មានលក្ខខណ្ឌ។

**ប្រការ៦៦.-ការលើកទឹកចិត្ត**

និស្សិតដែលគោរពវិន័យនិងសីលធម៌ល្អ និងជានិស្សិតឆ្នើមរបស់សាកលវិទ្យាល័យ នឹងត្រូវទទួលនូវការលើកទឹកចិត្ត ដូចខាងក្រោម ៖

- តាំងរូបថតនៅលើតារាងកិត្តិយស និងផ្សាយតាមព្រឹត្តិបត្ររបស់សាកលវិទ្យាល័យ
- ជូនលិខិត ឬប័ណ្ណសរសើរ
- ជូនរង្វាន់
- ផ្តល់អាហារូបករណ៍
- ចារឹកក្នុងឯកសារវាយតម្លៃរបស់និស្សិត
- មានអាទិភាពក្លាយជាសាស្ត្រាចារ្យរបស់សាកលវិទ្យាល័យ។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**ប្រការ៦៧.-និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីបទបញ្ជាផ្ទៃក្នុងនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦៨.-អង្គភាពនិងសុពលភាពអនុវត្តន៍**

គណៈគ្រប់គ្រង ប្រធានអង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ សាស្ត្រាចារ្យ និស្សិត និងផ្នែកពាក់ព័ន្ធត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុងនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៧...ខែធ្នូ ឆ្នាំ២០១៥

**សាកលវិទ្យាធិការ**

ស.អ.អ

សាកលវិទ្យាល័យ

**បណ្ឌិត ជា សុភាព**

**ចម្លងជូន**

-ក្រសួងអប់រំ យុវជន និងកីឡា "ដើម្បីជូនជ្រាប"

-ដូចប្រការ៦៨ "ដើម្បីអនុវត្ត"

-កាលប្បវត្តិ-ឯកសារ, អគប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប**
អង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ

# របាយការណ៍ប្រជុំពិភាក្សា ស្តីពី
# បទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ
# នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

សម័យប្រជុំ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែវិច្ឆិកា ថ្ងៃទីម្ភៃបី ចាប់ពីម៉ោង ពីរនិងសូន្យនាទីរសៀល នៅបន្ទប់ប្រជុំអគារ B អង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប បានរៀបចំការប្រជុំពិភាក្សាលើ «*បទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប*» ក្រោមអធិបតីភាពលោកបណ្ឌិត **ជា សុភាព** សាកលវិទ្យាធិការ និងគណៈគ្រប់គ្រងរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ដូចមានក្នុងបញ្ជីវត្តមានជូនភ្ជាប់មកជាមួយ។

ជាកិច្ចចាប់ផ្តើម លោកបណ្ឌិត **ជា សុភាព** បានមានមតិស្វាគមន៍ចំពោះគណៈគ្រប់គ្រងបុគ្គលិកអំពីការចូលរួមប្រជុំនិងបានអនុញ្ញាតឱ្យលោកបណ្ឌិត ទ្រី ចាន់ធុច ប្រធានអង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ ឡើងបង្ហាញអំពីសេចក្តីព្រាង ស្តីពី បទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប។

បន្ទាប់ពីបានការអនុញ្ញាតពីលោកបណ្ឌិតសាកលវិទ្យាធិការ លោក ទ្រី ចាន់ធុច បានធ្វើបទបង្ហាញជូនអង្គប្រជុំពីជំពូកនីមួយៗ ទៅតាមលំដាប់លំដោយនិងឱ្យអង្គប្រជុំពិនិត្យ និងផ្តល់ការកែលម្អ។

បទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រនេះ មានចំនួន ៩ជំពូក ស្មើនឹង ៦៨ប្រការ ដូចខាងក្រោម៖

## ជំពូកទី១
## បទបញ្ញត្តិទូទៅ

ប្រការ១.-គោលបំណង
ប្រការ២.-គោលដៅ
ប្រការ៣.-បញ្ញត្តិ

## ជំពូកទី២
## លក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសនិស្សិតឱ្យចូលរៀន
### ផ្នែកទី១ ៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ប្រការ៤.-នីតិវិធីនៃការជ្រើសរើសនិស្សិត
ប្រការ៥.-លក្ខខណ្ឌសម្រាប់ការជ្រើសរើស
ប្រការ៦.-សំណុំលិខិតនិស្សិត
ប្រការ៧.-ការរៀបចំយន្តការប្រឡងជ្រើសរើស
ប្រការ៨.-ការប្រកាសលទ្ធផលជ្រើសរើស

### ផ្នែកទី២ ៖ ថ្នាក់បណ្ឌិត

ប្រការ៩.-នីតិវិធីនៃការជ្រើសរើសនិស្សិត
ប្រការ១០.-លក្ខខណ្ឌសម្រាប់ការជ្រើសរើស
ប្រការ១១.-សំណុំលិខិតបេក្ខជន
ប្រការ១២.-ការរៀបចំយន្តការប្រឡងជ្រើសរើស
ប្រការ១៣.-យន្តការជ្រើសរើស
ប្រការ១៤.-ការប្រកាសលទ្ធផលជ្រើសរើស

## ជំពូកទី៣
## កម្មវិធីសិក្សានិងការបង្រៀន
### ផ្នែកទី១ ៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ប្រការ១៥.-រយៈពេលសិក្សា
ប្រការ១៦.-តាមរយៈការសិក្សាលើមុខវិជ្ជា
ប្រការ១៧.-តាមរយៈការសិក្សាលើមុខវិជ្ជានិងស្រាវជ្រាវ
ប្រការ១៨.-តាមរយៈការស្រាវជ្រាវ
ប្រការ១៩.-មុខវិជ្ជាបំពេញបន្ថែម
ប្រការ២០.-ខ្លឹមសារមុខវិជ្ជា

### ផ្នែកទី២ ៖ ថ្នាក់បណ្ឌិត

ប្រការ២១.-រយៈពេលសិក្សា
ប្រការ២២.-កម្មវិធីសិក្សាថ្នាក់បណ្ឌិតស្រាវជ្រាវ
ប្រការ២៣.-កម្មវិធីសិក្សាថ្នាក់បណ្ឌិតវិជ្ជាជីវៈ
ប្រការ២៥.-មុខវិជ្ជាកម្រិតបណ្ឌិត
ប្រការ២៦.-ខ្លឹមសារមុខវិជ្ជា

ផ្នែកទី៣ ៖ ការបង្រៀននិងការវាយតម្លៃលទ្ធផលសិក្សា
ប្រការ២៧.-ការបង្រៀន
ប្រការ២៨.-ការវាយតម្លៃលទ្ធផលសិក្សា
ប្រការ២៩.-ប្រព័ន្ធផ្តល់ពិន្ទុ និងនិទ្ទេស
ប្រការ៣០.-អបៀបគណនារកមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប
ជំពូកទី៤
លក្ខខណ្ឌនិងលក្ខណវិនិច្ឆ័យសម្រាប់ការបញ្ចប់ការសិក្សា
ផ្នែកទី១ ៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
ប្រការ៣១.-ការរៀបចំយន្តការប្រឡងបញ្ចប់ការសិក្សា
ប្រការ៣២.-គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃរបាយការណ៍ស្រាវជ្រាវ ឬគម្រោងស្រាវជ្រាវ
ប្រការ៣៣.-ការប្រកាសលទ្ធផលបញ្ចប់ការសិក្សា
ប្រការ៣៤.-គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃនិក្ខេបបទ
ប្រការ៣៥.-ការរៀបចំនិក្ខេបបទ
ប្រការ៣៦.-ការវាយតម្លៃនិក្ខេបបទ
ប្រការ៣៧.-ការវាយតម្លៃគម្រោងស្រាវជ្រាវពិស្តារ
ប្រការ៣៨.-ការការពារនិក្ខេបបទសាកល្បង
ប្រការ៤០.-ការការពារនិក្ខេបបទឡើងវិញ
ប្រការ៤១.-លក្ខខណ្ឌសម្រាប់អនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់
ប្រការ៤២.-ការបញ្ជូនលទ្ធផលបញ្ចប់
ផ្នែកទី២ ៖ ថ្នាក់បណ្ឌិត
ប្រការ៤៣.-គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃនិក្ខេបបទ
ប្រការ៤៤.-ការរៀបចំនិក្ខេបបទបណ្ឌិត
ប្រការ៤៥.-ការវាយតម្លៃនិក្ខេបបទ
ប្រការ៤៦.-ការវាយតម្លៃគម្រោងស្រាវជ្រាវពិស្តារ
ប្រការ៤៧.-ការការពារនិក្ខេបបទសាកល្បង
ប្រការ៤៨.-ការការពារនិក្ខេបបទបញ្ចប់ការសិក្សា
ប្រការ៤៩.-ការការពារនិក្ខេបបទឡើងវិញ
ប្រការ៥០.-លក្ខខណ្ឌសម្រាប់អនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់
ប្រការ៥១.-ការបញ្ជូនលទ្ធផលបញ្ចប់
ជំពូកទី៥
វិន័យនិងសីលធម៌
ប្រការ៥២.-ការបង់ថ្លៃសិក្សា
ប្រការ៥៣.-ឯកសណ្ឋាននិស្សិត
ប្រការ៥៤.-អំពីការសិក្សា

ប្រការ៥៥.-ការព្យួរការសិក្សា
ប្រការ៥៦.-អំពីសីលធម៌
ប្រការ៥៧.-ករណីអវត្តមាន ឥតច្បាប់
ប្រការ៥៨.-ករណីអវត្តមាន មានច្បាប់
ប្រការ៥៩.-ការប្រឡង
ប្រការ៦០.-ករណីកំហុសក្នុងពេលប្រឡង

ជំពូកទី៦

សិល្បៈ វប្បធម៌ សហគមន៍ កីឡា និងការចូលរួមក្នុងកម្មវិធីផ្សេងៗ

ប្រការ៦១.-អំពីសិល្បៈ វប្បធម៌ និងសហគមន៍
ប្រការ៦២.-អំពីកីឡា
ប្រការ៦៣.-សេវាសុខភាព
ប្រការ៦៤.-ការចូលរួមកម្មវិធីផ្សេងៗ

ជំពូកទី៧

វិធានការរដ្ឋបាល និងការលើកទឹកចិត្ត

ប្រការ៦៥.-វិធានការរដ្ឋបាល
ប្រការ៦៦.-ការលើកទឹកចិត្ត

ជំពូកទី៨

អវសានប្បញ្ញត្តិ

ប្រការ៦៧.-និរាករណ៍
ប្រការ៦៨.-អង្គភាពនិងសុពលភាពអនុវត្តន៍

ក្រោយពីបានធ្វើការពិភាក្សា និងការពិនិត្យយ៉ាងយកចិត្តទុកដាក់ខ្ពស់លើខ្លឹមសាររួមនៃសេចក្តីព្រាង ស្តីពី បទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រនៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប នេះរួចមក អង្គប្រជុំក៏បានធ្វើការសម្រេចទៅលើបទបញ្ជាផ្ទៃក្នុងនេះដែលមានចំនួន ៨ជំពូក ស្មើនឹង ៦៨ប្រការ។

អង្គប្រជុំទាំងមូលបានបញ្ចប់នៅវេលាម៉ោង ប្រាំនិងសូន្យនាទីរសៀល នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទ្ធស្នាល និងមានទំនួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៥

**អ្នកធ្វើរបាយការណ៍**

(ហត្ថលេខា)

**បានឃើញនិងឯកភាព**

**ប្រធានអង្គប្រជុំ**

(ហត្ថលេខា)

បណ្ឌិត ជា សុភាព

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប**
អង្គភាពគ្រប់គ្រងថ្នាក់ក្រោយបរិញ្ញាបត្រ

# បញ្ជីសម្រង់វត្តមានប្រជុំពិភាក្សានិងអនុម័ត
## ស្តីពី
## «បទបញ្ជាផ្ទៃក្នុងសម្រាប់សាស្ត្រាចារ្យថ្នាក់ក្រោយបរិញ្ញាបត្រ និងបទបញ្ជាផ្ទៃក្នុងសម្រាប់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រ នៃសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប»

ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៥

| ល.រ | គោត្តនាម-នាម | English Name | ភេទ | មុខតំណែង | E-mail | លេខទូរសព្ទ | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| 01 | ជា សុភាព | Chea Sopheap | ប | [illegible] | chea_sopheap@aeu.edu.kh | 012525536 | |
| 02 | សួរ ប៊ុនសូ | Sour Bunsou | ប | VR | sourbunsou@aeu.edu.kh | 016970096 | |
| 03 | ស៊ិន សេដ្ឋា | setha@aeu.edu.kh | ប | [illegible] | setha@aeu.edu.kh | 012523768 | |
| 04 | គង់ វីរៈ | KONG Vireak | | [illegible] | kongvireak@gmail.com | 017499399 | |
| 05 | កែវ សាវី | Keo Savy | ស | ប្រធានបណ្ណាល័យ | savy_keo@aeu.edu.kh | 092622238 | |
| 06 | សុត សំម៉ាង | SOT Saumang | ប | VR | sammang@aeu.edu.kh | 017601666 | |
| 07 | សំ សុភី | SAM Sophy | ប | Dean, FAHL | samsophy@aeu.edu.kh | 012228921 | |
| 08 | ទីម សុខុម | Tim Sokhom | ប | Head of EEO | timsokhom@gmail.com | 017270686 | |
| 09 | បណ្ឌិត ទ្រី ចាន់ធុច | Dr. Try Chanthuch | ប | Director, PGU | chanthuch@aeu.edu.kh | 017799889 | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | សូស សុភា | Sous Sophea | ប | ប្រធាន FDY | sophea@aeu.edu.kh | 078 777068 | [signature] |
| 11 | ប៊ូ ឈុន | Bou Chhun | ប | Vice Dean of IT | bouchhun@aeu.edu.kh | 016 333 188 | [signature] |
| 12 | រស់ សំអុន | Ros Samonn | ប | [illegible] | samonnros@gmail.com | 012320698 | [signature] |
| 13 | ភួន វណ្ណៈ | Phoun Vannak | ប | Vice Dean Fbat | vannakphoun@aeu.edu.kh | 012566686 | [signature] |
| 14 | ហុង សុវណ្ណដា | Hong Sovannda | H | PG4- | h-sovannda@aeu.edu.kh | 07748414 | [signature] |
| 15 | សិប សក្កណៈ | Sib Sakranak | M | [illegible] | sakranaksib@aeu.edu.kh | 086768687 | [signature] |
| 16 | វ៉ា វិទ្ធានៈ | Va Voithanak | M | [illegible] | Voithanak@aeu@gmail.com | 092626478 | [signature] |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

រាជធានីភ្នំពេញ ថ្ងៃទី...២៧...ខែ...វិច្ឆិកា.....ឆ្នាំ២០១៥

លេខាកត់ត្រា

[signature]

ហុង សុវណ្ណដា